# សេចក្ដីផ្ដើម

## ចរិតលក្ខណៈនៃកម្មវិធីសុខភាពសិក្សា៖ តើត្រូវរៀន និងបង្រៀនយ៉ាងដូចម្ដេច?

### គោលបំណងមេរៀន

អ្នកសិក្សានឹងអាចយល់ និងពន្យល់អំពី៖
- អត្ថន័យនៃការរស់នៅប្រកបដោយសុខភាពល្អរបស់មនុស្សនៅក្នុងវដ្តជីវិតរបស់ពួកគេ
- ចរិតលក្ខណៈ និងសារៈសំខាន់នៃសុខភាពសិក្សាក្នុងនាមជាមុខវិជ្ជាសិក្សាមួយ
- សុខភាពគឺជាបញ្ហាផ្ទាល់ខ្លួន
- ទំនាក់ទំនងរវាងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDGs) ទាំង ១៧ និងសុខភាពសិក្សា
- ហេតុអ្វីបានជាមានសារៈសំខាន់សម្រាប់សិស្សានុសិស្សដែលប្រាថ្នាចង់ក្លាយជាគ្រូបង្រៀនឱ្យសិក្សា និងបង្រៀនមុខវិជ្ជាសុខភាពសិក្សានេះដល់កុមារ និងក្នុងការបង្កើនចំណាប់អារម្មណ៍របស់សិស្សចំពោះខ្លឹមសារនៃសៀវភៅសិក្សានេះដែលរួមមាន ១៦ជំពូក

ដោយមានគោលដៅផ្ដោតលើគរុសិស្សក្នុងវគ្គបណ្ដុះបណ្ដាលគ្រូបង្រៀនដែលប្រើប្រាស់សៀវភៅសិក្សានេះដើម្បីសិក្សាហើយនឹងបង្រៀនអំពីសុខភាពសិក្សាដល់កុមារនាពេលអនាគត សៀវភៅនេះពិភាក្សាអំពីចរិតលក្ខណៈនៃមុខវិជ្ជាសុខភាពសិក្សា របៀបសិក្សា និងវិធីសាស្ត្របង្រៀនមុខវិជ្ជានេះ និងចំណុចនានាដែលគរុសិស្សគួរយល់បន្ថែម។

## ១ តើមនុស្សមានសុខភាពល្អពេញមួយជីវិតមានន័យដូចម្ដេច?

តើវាមានន័យដូចម្ដេចដើម្បីឱ្យបុគ្គលរស់នៅប្រកបដោយសុខភាពល្អពេញមួយជីវិត? សុខភាពរបស់មនុស្សចាប់ផ្ដើមនៅពេលដែលមេជីវិតឈ្មោលដែលមានសុខភាពល្អជួបនឹងពងញីដែលមានសុខភាពល្អ ជាលទ្ធផលបណ្ដាលឱ្យមានការបង្កកំណើតប្រកបដោយសុខភាពល្អ (**រូបទី ០.១**)។ ពងញីបង្កកំណើតដែលមានសុខភាពល្អធ្វើបំណែងចែក ហើយទីបំផុតបង្កើតជាគភ៌ដែលលូតលាស់ និងអភិវឌ្ឍប្រកបដោយសុខភាពល្អនៅក្នុងផ្ទៃម្ដាយដែលមានសុខភាពល្អ ហើយកើតមកមានសុខភាពល្អតាមរយៈការសម្រាលដែលមានសុខភាពល្អត្រឹមត្រូវនៅពេលគ្រប់ខែ។ ទារកលូតលាស់ និងអភិវឌ្ឍប្រកបដោយសុខភាពល្អ ហើយនៅទីបំផុតក៏ពេញវ័យ ទាំងផ្នែកផ្លូវភេទផងដែរ។ មនុស្សពេញវ័យដែលមានសុខភាពល្អនឹងប្រកបការងារដោយរីករាយ ពេញចិត្តនឹងជីវិត ហើយនៅទីបំផុតមានគ្រួសារមួយ។ បុរសនិងស្ត្រីដែលមានសុខភាពល្អបង្កើតមេជីវិតឈ្មោល និងពងញីដែលមានសុខភាពល្អនៅក្នុងសរីរាង្គបន្តពូជរបស់ពួកគេ ហើយបញ្ជូនបន្តព័ត៌មានជីវិតនៅក្នុង ADN ទៅជំនាន់ក្រោយៗទៀត។ ជីវិតក៏អនុវត្តនូវវដ្តជីវិតនេះដដែរៗម្ដងហើយម្ដងទៀត។

នៅពេលដែលមនុស្សឈានដល់ភាពពេញវ័យ និងវ័យយុវវ័យប្រកបដោយសុខភាពល្អ ពួកគេឆ្លងកាត់ដំណើរវិវឌ្ឍទៅវ័យចំណាស់ទៅតាមច្បាប់នៃជីវិតមនុស្ស។ ពួកគេវិវឌ្ឍទៅវ័យចំណាស់ប្រកបដោយសុខភាពល្អរហូតអវសាននៃជីវិតរបស់ពួកគេ។ ពួកគេរស់នៅប្រកបដោយសុខភាពល្អតាមរបៀបពិសេសនៅថ្ងៃចុងក្រោយរបស់ពួកគេ ហើយទីបំផុតក៏ស្លាប់ប្រកបដោយសេចក្ដីថ្លៃថ្នូរជាមនុស្ស។ ជីវិតបន្ទាប់គឺជាពិភពមួយដែលមិនស្គាល់។ វាមានពិភពដ៏ពិសិដ្ឋមួយដែលខុសគ្នាទៅតាមសាសនានីមួយៗ។ អ្នកខ្លះប្រហែលជាមិនជឿលើវត្តមាននៃពិភពបែបនេះទេ។




**រូបទី ០.១៖** វដ្ដជីវិត និងវដ្ដសុខភាពរបស់មនុស្ស

## ២ សារៈសំខាន់នៃការរៀន និងបង្រៀនមុខវិជ្ជាសុខភាពសិក្សា

ប្រសិនបើមនុស្សអាចរស់នៅប្រកបដោយ «សុខភាព» ដ៏ល្អឥតខ្ចោះដូចដែលបានបង្ហាញនៅក្នុងដ្យាក្រាមនេះ វាគឺជាអព្ភូតហេតុ និងមិនអាចកើតមាននៅក្នុងជីវិតជាក់ស្ដែងឡើយ។ ដំណើរស្វែងរកសុខភាពល្អឥតខ្ចោះដោយគ្មានការគិតពិចារណាអំពីដែនកំណត់របស់មនុស្ស និងសង្គមមានទេនោះ វានឹងនាំទៅរក**បញ្ញត្តិនៃសុជាតិវិទ្យា (concept of eugenics)** ជាលទ្ធផលវាអាចបណ្ដាលឱ្យមានការដកខ្លួនចេញពីសង្គមទាំងស្រុង លើកលែងតែអ្នកដែលអាចគិតពិចារណាត្រឹមថា «មានសុខភាពល្អធម្មតា» ប៉ុណ្ណោះ។ ដោយសារតែគ្មានទេមនុស្សដែលល្អឥតខ្ចោះនេះហើយ ទើបយើងមិនត្រូវធ្លាក់ក្នុងអន្ទាក់នៃសុខភាពនិយមនោះឡើយ (ដំណើរស្វែងរកសុខភាពដែលជាវត្ថុដ៏មានតម្លៃបំផុត)។

នៅចំណុចមួយនៃវដ្ដជីវិត មនុស្សគ្រប់រូបជួបប្រទះនូវស្ថានភាព បរិស្ថាន និងលក្ខខណ្ឌនានាដែលជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់សុខភាពរបស់ពួកគេ ព្រមទាំងទទួលរងនូវបញ្ហាប្រឈមផ្នែកសុខភាពដូចជាជំងឺ របួស ពិការភាព និងសុខភាពមិនល្អក្នុងកម្រិតណាមួយ។ ទោះយូរ ឬឆាប់ យើងមិនអាចគេចផុតពីជោគវាសនារបស់មនុស្ស ឬសេចក្ដីស្លាប់នេះដែរ។ និយាយម្យ៉ាងទៀត ខណៈពេលដែលពេលវេលានៃការស្លាប់ប្រហែលជាមិនស្មើគ្នា យើងទាំងអស់គ្នាប្រឈមមុខស្មើគ្នាចំពោះវត្តមាននៃជោគវាសនា ពោលគឺគ្មាននរណាម្នាក់អាចរួចផុតពីសេចក្ដីស្លាប់នោះទេ។

ទោះជាយ៉ាងណាក៏ដោយ មនុស្សភាគច្រើនចង់រស់នៅឱ្យបានយូរតាមដែលអាចធ្វើទៅបានប្រកបដោយសុខភាពល្អ ហើយថែមទាំងនាំទៅកាន់ជីវិតសប្បុរសប្បាយច្រើនតាមដែលអាចធ្វើទៅបាន។ តើការអប់រំ និងសាលារៀនអាចធ្វើអ្វីខ្លះដើម្បីសម្រេចបំណងនេះ? សុខភាពសិក្សាគឺជាគំនិតផ្ដួចផ្ដើមមួយដែលប្រមូលផ្ដុំគ្រូបង្រៀននិងបុគ្គលិកសិក្សា ក្រុមគ្រួសារ និងសាច់ញាតិ និងសមាជិកក្នុងសហគមន៍មកធ្វើការរួមគ្នាដើម្បីបំពេញនូវបំណងប្រាថ្នាចង់រស់នៅប្រកបដោយសុខភាពល្អ ដោយផ្ដោតលើសុខភាពរបស់ក្រុមកុមារកំពុងនៅក្នុងវ័យសិក្សា។ តួនាទីនៃ «សុខភាពល្អឥតខ្ចោះ» ដែលបានកំណត់ដោយអង្គការសុខភាពពិភពលោក WHO (សូមមើលជំពូកទី ១) ត្រូវបានគេមើលឃើញថាជាមគ្គុទ្ទេសន៍អំពីរបៀបដែលយើងគួររស់រានមានជីវិត និងដឹកនាំជីវិតប្រចាំថ្ងៃរបស់យើងគឺដូចជាចាស់បុរាណបានធ្វើដំណើរឆ្លងកាត់សមុទ្រនៅពេលយប់ឆ្ពោះទៅរកគោលដៅរបស់ពួកគេដោយធ្វើដំណើរតាមគន្លងកាត់គ្នារវាងតារាភាគខាងជើង និងតារាភាគខាងត្បូង (North Star and the Southern Cross)។ គោលដៅអាចសម្រេចបានគឺ «សុខភាពកាន់តែប្រសើរ» ដោយពិចារណាទៅលើភាពមានកម្រិតរបស់មនុស្ស និងសង្គម។

ដោយសារមាន**ភាពចម្រុះនៃរូបរាងកាយ ការអភិវឌ្ឍ ផ្លូវភេទ និងសង្គមវប្បធម៌** វាមានសារៈសំខាន់ក្នុងការសម្គាល់ថា «សុខភាព» មិនមែនជាព្រឹត្តិការណ៍តែមួយទេ ប៉ុន្តែសុខភាពជាវិសាលគមមួយដែលរួមផ្សំដោយកម្រិតផ្សេងៗសុខភាព និងបញ្ញត្តិដែលមានគុណតម្លៃផ្សេងៗគ្នា។ ដោយអាស្រ័យលើវប្បធម៌ ប្រវត្តិសាស្ត្រ សាសនា ជាតិសាសន៍ យេនឌ័រ ជាដើមនៃប្រទេស សង្គម និងតំបន់មួយ វាមានទស្សនៈផ្សេងៗគ្នានៃចំពោះសុខភាព។

ក្នុងសង្គមបច្ចុប្បន្ន វាចាំបាច់ត្រូវបង្រៀនអំពីសុខភាពដោយផ្អែកលើចំណេះដឹងដែលមានស្រាប់ និងចំណេះដឹងដែលបានប្រមូលផ្តុំតាមវិធីសាស្ត្រវិទ្យាសាស្ត្រ ហើយក្នុងពេលដំណាលគ្នានេះពិចារណាពីវិធីគិតបែបចម្រុះទាំងនេះអំពីសុខភាព។ យោងតាមសេចក្តីនេះដើម្បីរស់នៅក្នុងជីវិតមួយប្រកបដោយសុខភាពល្អមានន័យថាត្រូវបញ្ចូលនូវគតិបណ្ឌិតដ៏សម្បូរបែបអំពីសុខភាពដែលមានឫសគល់ពីបទពិសោធន៍ និងជីវិតប្រចាំថ្ងៃរបស់យើង (ឧទាហរណ៍ របៀបថែទាំខ្លួនឯង របៀបប្រើប្រាស់ថ្នាំដោយខ្លួនឯង របៀបបង្ការខ្លួនឯង និងរុក្ខជាតិឱសថ) ជាមួយនឹងចំណេះដឹងវិទ្យាសាស្ត្រត្រឹមត្រូវអំពីសុខភាព និងដើម្បីអនុវត្ត ព្រមទាំងបញ្ជាក់ពីវានៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង និងដើម្បីកែលម្អជីវិត និងរបៀបរស់នៅរបស់យើងដោយខ្លួនឯង។ ពេលខ្លះ វាចាំបាច់ត្រូវស្វែងរកជំនួយពីសហគមន៍ និងអ្នកដទៃដើម្បីរស់នៅប្រកបដោយសុខភាពល្អ។

ទោះជាយ៉ាងណាក៏ដោយ វិសាលភាពនៃអ្វីដែលមនុស្សដឹង**អំពីអាថ៌កំបាំងជុំវិញសុខភាព**នៅមានកម្រិត។ ហេតុនេះហើយ ឥរិយាបថនៃការដឹងអំពីភាពព្រងើយកន្តើយរបស់យើង និងភាពរម្យទមរបស់យើងក្នុងការអនុវត្តនូវ**គតិបណ្ឌិត និងចំណេះដឹងអំពីសុខភាព**ក្នុងជីវិតប្រចាំថ្ងៃរបស់យើងគឺជាផ្នត់គំនិតដែលអនុញ្ញាតឱ្យយើងគិតពីសុខភាពថាជាកម្មសិទ្ធិរបស់យើងផ្ទាល់ ហើយជាគោលជំហរតម្រូវឱ្យមានពីអ្នកដែលរៀន និងអ្នកបង្រៀនមុខវិជ្ជាសុខភាពសិក្សា។

សៀវភៅសិក្សានេះពិភាក្សាអំពីខ្លឹមសារនៃវគ្គសុខភាពសិក្សាកម្រិតបឋមសិក្សាដែលទើបដាក់ឱ្យប្រើប្រាស់ថ្មីជាលើកដំបូង។ ពោលគឺសៀវភៅសិក្សានេះមាន ១៦ជំពូក ដែលនិស្សិតសាកលវិទ្យាល័យគួរសិក្សាដើម្បីក្លាយជាគ្រូបង្រៀនប្រកបដោយលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការរៀន និងបង្រៀនមុខវិជ្ជាសុខភាពសិក្សា។ ជំពូកទាំង ១៦ នេះមានខ្លឹមសារសុខភាពសិក្សា ដែលនឹងមិនត្រឹមតែមានប្រយោជន៍សម្រាប់អ្នកនៅពេលអ្នកក្លាយជាគ្រូបង្រៀនប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងជួយអ្នកឱ្យយល់អំពីសុខភាពរបស់អ្នក សុខភាពរបស់គ្រួសារ និងមិត្តភក្តិរបស់អ្នក ព្រមទាំងសុខភាពរបស់ប្រជាជនកម្ពុជាផងដែរ។ វាមានសារៈសំខាន់ដែលអ្នកត្រូវយកខ្លឹមសារនៃជំពូកនីមួយៗធ្វើជាបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក និងជាអ្វីដែលត្រូវឆ្លុះបញ្ចាំងអំពីវា ហើយសិក្សាខ្លឹមសារទាំងនេះជាបញ្ហាផ្ទាល់ខ្លួនរបស់អ្នក មិនមែនជារបស់អ្នកដទៃនោះទេ។ អ្នកអាចសិក្សាអំពី**លំហាត់**នៅចុងបញ្ចប់នៃជំពូកនីមួយៗ ហើយពិភាក្សាលំហាត់នោះនៅក្នុងថ្នាក់ដើម្បីឱ្យការសិក្សារបស់អ្នកកាន់តែស៊ីជម្រៅ។

**អត្ថបទជកស្រង់ ០.១៖ ជំងឺ ពិការភាព និងបញ្ញត្តិនៃសុជាតិវិទ្យា**

***សុជាតិវិទ្យា*** *(Eugenics) គឺជាមុខវិជ្ជាសិក្សាមួយដែលត្រូវបានគេជឿថាមនុស្សមានពីរប្រភេទគឺ៖ មនុស្សដែលមានលក្ខណៈជីវសាស្ត្រល្អ និងមនុស្សដែលមានលក្ខណៈជីវសាស្ត្រមិនល្អ។ វាស្វែងរកនេះការកែលម្អគុណភាពរបស់មនុស្សដោយរក្សាអ្នកដែលមានលក្ខណៈសែនល្អ និងលុបបំបាត់អ្នកដែលមានកត្តាសែនអន់។ ប្រឆាំងផ្ទុយនឹងសារគោរនៃចំណេះដឹងនេះ បញ្ញត្តិនៃសុជាតិវិទ្យាគឺជាជំនឿដែលជឿថាមានមនុស្សដែលមានគុណសម្បត្តិសមនឹងរស់នៅ និងអ្នកដែលគ្មានគុណសម្បត្តិសមនឹងរស់នៅ។ វាកំណត់ឧត្តមភាព និងភាពអន់ថយដល់ជីវិតមនុស្ស។ លក្ខណៈវិនិច្ឆ័យសំខាន់បំផុតដែលប្រើដើម្បីកំណត់ឧត្តមភាពនិងភាពអន់ថយ ក្នុងអតីតកាលនិងបច្ចុប្បន្នកាលគឺ ពិការភាព ជំងឺ ពូជសាសន៍/ជនជាតិ និងអាយុ។*

## ៣ ចរិតលក្ខណៈនៃសុខភាពសិក្សាជាមុខវិជ្ជាមួយ

ដើម្បីបង្រៀន និងរៀនអំពីសុខភាពនៅតាមសាលារៀន បុគ្គលម្នាក់ៗគួរតែស្វែងយល់ឱ្យបានទូលំទូលាយអំពីសុខភាពមនុស្សទាក់ទងនឹងរាងកាយ ចិត្តវិទ្យា អាកប្បកិរិយា បរិយាកាសសង្គម និងបរិស្ថានធម្មជាតិ ហើយអនុវត្តនូវអ្វីដែលបានរៀននៅក្នុងជីវិតប្រចាំថ្ងៃ។ ជាពិសេស ការបង្រៀន និងការរៀនអំពីសុខភាពនៅតាមសាលារៀនមានន័យថាការផ្ទេរចំណេះដឹងបែបវិទ្យាសាស្ត្រអំពីសុខភាព និងជំនាញរស់នៅត្រឹមត្រូវដល់សិស្សានុសិស្សដើម្បីជួយពួកគេអនុវត្តការរស់នៅប្រកបដោយសុខភាពល្អ។

គន្លឹះក្នុងការសម្រេចបានការផ្ទេរចំណេះដឹងនេះគឺការប្រាស្រ័យទាក់ទងរវាងអ្នកបង្រៀន និងអ្នករៀន (រួមទាំងវិធីសាស្ត្របង្រៀន ពោលគឺរបៀបបង្រៀនអំពីមុខវិជ្ជាសុខភាព)។ តាមពិតទៅ វាមានពិភពពីរ៖ ពិភពមួយសម្រាប់គ្រូបង្រៀន និងពិភពមួយទៀតសម្រាប់សិស្ស កុមារ និងជីវិតសាធារណជនទូទៅ។ ចំណេះដឹង និងសុភវិនិច្ឆ័យអំពីសុខភាពមានភាពខុសគ្នារវាងពិភពទាំងពីរនេះ។ ភាសាដែលកំពុងប្រើក៏មានភាពខុសគ្នាដែរ។

ពិតណាស់ ពិភពជីវិតទាំងពីរនេះមានភាពត្រួតគ្នា។ គ្រូបង្រៀនស្គាល់ច្បាស់ពីពិភពទាំងពីរ៖ ពិភពមួយប្រើប្រាស់វិជ្ជាជីវៈ និងចំណេះដឹងវិទ្យាសាស្ត្រ ហើយពិភពមួយទៀតពឹងផ្អែកលើគតិបណ្ឌិតទូទៅ និងគតិបណ្ឌិតបែបប្រពៃណី។ វាដើរតួយ៉ាងសំខាន់ក្នុងការភ្ជាប់ទំនាក់ទំនងពិភពទាំងពីរ (**រូបទី ០.២**)។ និយាយម្យ៉ាងទៀត តួនាទីនេះ គឺជាផ្នែក**អប់រំសុខភាព-អ្នកផ្ទេរចំណេះដឹង**។

ក្នុងការអប់រំសុខភាព វាចាំបាច់ត្រូវផ្ទេរចំណេះដឹងឯកទេសដល់សិស្សានុសិស្ស កុមារ និងសាធារណជនទូទៅក្នុងតរិយាបថងាយស្រួលយល់មួយ ដែលអាចជួយឱ្យពួកគេផ្លាស់ប្តូរអាកប្បកិរិយា និងការគិតរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ចំណុចមួយនេះតែងនឹងនាំមកនូវលទ្ធផលដែលគ្រូបង្រៀនជាអ្នកផ្តល់ចំណេះដឹងតែម្ខាងជាឯកតោភាគីដល់និស្សិត និងសិស្ស។ ដោយសារចំណេះដឹងអំពីសុខភាពតាមបែបវិទ្យាសាស្ត្រមានលក្ខណៈជាសកល វាប្រហែលជាមិនចាំបាច់ត្រូវឆ្លើយតបទៅនឹងសុខភាព របៀបរស់នៅ ឬបរិស្ថានរបស់បុគ្គលម្នាក់ៗឡើយ (ឧទាហរណ៍ ត្រូវគិតអំពីវប្បធម៌នៃអាហារប្រពៃណី និងរបៀបរកគ្រឿងផ្សំនៅក្នុងតំបន់មួយៗ)។ នេះជាមូលហេតុដែលធ្វើឱ្យគតិបណ្ឌិតនៃសុខភាពដែលមាននៅក្នុងជីវិតប្រចាំថ្ងៃរបស់យើងមានតម្លៃណាស់។ វាប្រហែលជាបម្រើគោលបំណងនៃការអនុវត្តជាក់ស្តែងពិតមែន ពីព្រោះវាជាការប្រមូលផ្តុំនូវបទពិសោធន៍ដែលសមស្របទៅនឹងចរិតលក្ខណៈរាងកាយ និងបុគ្គលិកលក្ខណៈ របៀបរស់នៅក្នុងតំបន់ និងបរិយាកាសរស់នៅរបស់បុគ្គលម្នាក់ៗ។ ជាការពិតណាស់ មានការអនុវត្តមួយចំនួនដែលចាំបាច់ត្រូវផ្លាស់ប្តូរពីទស្សនវិស័យគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) រួមទាំងបទដ្ឋានផ្លូវភេទតាមប្រពៃណីរបស់ប្រទេសកម្ពុជា និងវប្បធម៌ក្នុងការសម្រាលកូនក៏ដូចជាអាពាហ៍ពិពាហ៍កុមារ និងការកាត់ប្រដាប់បន្តពូជស្ត្រីដែលគេឃើញកើតឡើងនៅជុំវិញពិភពលោក (សូមមើលជំពូកទី ១១)។

ដូច្នេះការអប់រំសុខភាពតម្រូវឱ្យអ្នកយល់ច្បាស់ និងគោរពនូវប្រពៃណី ទំនៀមទម្លាប់ គតិបណ្ឌិត និងគំនិតរបស់សហគមន៍មូលដ្ឋានក៏ដូចជាប្រាស្រ័យទាក់ទងគ្នាដោយបកប្រែចំណេះដឹងវិទ្យាសាស្ត្រតាមរបៀបដែលងាយយល់ និងអនុវត្តក្នុងជីវិតប្រចាំថ្ងៃ។ សេចក្តីនេះអាចទាក់ទងទៅនឹងការប្រើប្រាស់វាក្យស័ព្ទវិទ្យាសាស្ត្រ បច្ចេកទេស ឬការបកប្រែពាក្យបច្ចេកទេសទៅជាភាសាដែលប្រើក្នុងជីវិតប្រចាំថ្ងៃ វាទាមទារភាពបត់បែនដើម្បីសម្របទៅតាមកាលៈទេសៈ។

ការអប់រំសុខភាពនៅប្រទេសកម្ពុជាគួរតែផ្តោតលើការស្វែងយល់ពីរបៀបរស់នៅប្រកបដោយសុខភាពល្អដែលទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធសុខភាព និងសុខុមាលភាព និងសេវាកម្មនានាដែលនឹងត្រូវអភិវឌ្ឍក្នុងស្រុកនាពេលអនាគត និងពីស្ថាប័ននៃចំណេះដឹងផ្នែកវិទ្យាសាស្ត្រអំពីសុខាភិបាល និងវេជ្ជសាស្ត្រដែលកំពុងលេចឡើងនៅជុំវិញពិភពលោក ខណៈរក្សាឱ្យបានច្រើនតាមដែលអាចធ្វើទៅបាននូវវប្បធម៌ និងបរិស្ថានវិទ្យានៃការរស់នៅក្នុងតំបន់ដែលការអភិវឌ្ឍសេដ្ឋកិច្ចនឹងត្រូវបានធ្វើ។

ក្នុងបែបបទនេះ ការអប់រំសុខភាពក្នុងសាលារៀន ស្វែងរកការបណ្ដុះសមត្ថភាពរបស់និស្សិតនិងកុមារដើម្បីរស់នៅប្រកបដោយសុខភាពល្អក៏ដូចជាបង្កើតសង្គម និងបរិស្ថានដែលមនុស្សគ្រប់រូបក្នុងសហគមន៍អាចរស់នៅប្រកបដោយសុខភាពល្អ។




**រូបទី ០.២៖** ទំនាក់ទំនងទៅវិញទៅមកទាំងពីរនៃការអប់រំសុខភាពក្នុងកម្មវិធីសុខភាពសិក្សា

## ៤ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) និងសុខភាពសិក្សា

ប្រធានបទចុងក្រោយគឺទំនាក់ទំនងរវាង SDGs និងសុខភាពសិក្សា។ SDGs គឺជាគោលដៅបន្តពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) ដែលបានកំណត់នៅក្នុងកិច្ចប្រជុំកំពូលរបស់អង្គការសហប្រជាជាតិ (UN) ក្នុងឆ្នាំ២០១៥ ជាគោលដៅ ឬបញ្ហាប្រឈមដើម្បីសម្រេចបាននូវពិភពលោកប្រកបដោយនិរន្តរភាព និងប្រសើរជាងមុននៅឆ្នាំ២០៣០។ នៅក្នុងន័យនេះ SDGs គឺជាសំណុំនៃគោលដៅដែលពិភពលោកទាំងមូលត្រូវធ្វើដោយមិនគិតពីកម្រិតសេដ្ឋកិច្ច ឬការអភិវឌ្ឍដើម្បីឱ្យមនុស្សជាតិរស់រានមានជីវិត និងរីកចម្រើនប្រកបដោយចីរភាពនៅលើភពផែនដីនេះ។ ជាការពិតណាស់ កម្ពុជាក៏កំពុងព្យាយាមសង្កត់ធ្ងន់លើគោលដៅ SDGs នេះដែរ។[1]

SDGs រួមមាន ១៧គោលដៅ និង ១៦៩ចំណុចនៅក្រោមគោលដៅទាំងនេះ។ គោលដៅទាំង ១៧ មានដូចខាងក្រោម៖

**គោលដៅទី ១៖** លុបបំបាត់**ភាពក្រីក្រ**គ្រប់ទម្រង់នៅគ្រប់ទីកន្លែង

**គោលដៅទី ២៖** លុបបំបាត់**ភាពអត់ឃ្លាន** សម្រេចបាននូវ**សន្តិសុខស្បៀង** និងការកែលម្អ**អាហារូបត្ថម្ភ** និងលើកកម្ពស់**វិស័យកសិកម្មប្រកបដោយនិរន្តរភាព**

**គោលដៅទី ៣៖** ធានាបាននូវ**ជីវិតដែលមានសុខភាពល្អ** និងលើកកម្ពស់**សុខុមាលភាព**សម្រាប់មនុស្សគ្រប់វ័យ

**គោលដៅទី ៤៖** ធានាឱ្យមានការអប់រំប្រកបដោយ**គុណភាព** សមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាស**សិក្សាពេញមួយជីវិត**សម្រាប់ទាំងអស់គ្នា

**គោលដៅទី ៥៖** សម្រេចបាននូវ**សមភាពយេនឌ័រ** និងផ្ដល់សិទ្ធិអំណាចដល់ស្ត្រីនិងកុមារីគ្រប់រូប

**គោលដៅទី ៦៖** ធានាឱ្យមានលទ្ធភាពទទួលបាន និងការគ្រប់គ្រង**ទឹកនិងអនាម័យ**ប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា

**គោលដៅទី ៧៖** ធានាឱ្យមានលទ្ធភាពទទួលបាន**ថាមពល**ដែលអាចជឿទុកចិត្តបាន ប្រកបដោយនិរន្តរភាព និងទំនើបសម្រាប់ទាំងអស់គ្នា

**គោលដៅទី ៨៖** លើកកម្ពស់**កំណើនសេដ្ឋកិច្ច**ប្រកបដោយចីរភាព បរិយាបន្ន និងនិរន្តរភាពការងារពេញលេញ ព្រមទាំងផលិតភាពនិង**ការងារសមរម្យ**សម្រាប់ទាំងអស់គ្នា

**គោលដៅទី ៩៖** កសាង**ហេដ្ឋារចនាសម្ព័ន្ធ**ធន់ ជំរុញ**ឧស្សាហូបនីយកម្ម**ប្រកបដោយបរិយាបន្ននិងនិរន្តរភាព ព្រមទាំងជំរុញការច្នៃប្រឌិត

**គោលដៅទី ១០៖** កាត់បន្ថយ**វិសមភាព**ក្នុងប្រទេស និងក្នុងចំណោមបណ្ដាប្រទេស

**គោលដៅទី ១១៖** ធ្វើឱ្យ**ទីក្រុង** និង**ការតាំងទីលំនៅរបស់មនុស្សប្រកបដោយបរិយាបន្ន សុវត្ថិភាព** ភាពធន់ និងមានចីរភាព

**គោលដៅទី ១២៖** ធានានូវគំរូនៃ**ការប្រើប្រាស់** និង**ផលិតកម្ម**ប្រកបដោយនិរន្តរភាព

**គោលដៅទី ១៣៖** ចាត់វិធានការបន្ទាន់ដើម្បីប្រយុទ្ធប្រឆាំងនឹង**ការប្រែប្រួលអាកាសធាតុ** និងផលប៉ះពាល់របស់វា

**គោលដៅទី ១៤៖** អភិរក្ស និងប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃ**មហាសមុទ្រ សមុទ្រ** និង**ធនធានសមុទ្រ**សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

**គោលដៅទី ១៥៖** ការពារ ស្ដារ និងលើកកម្ពស់ការប្រើប្រាស់**ប្រព័ន្ធជីវចម្រុះលើដី**ប្រកបដោយនិរន្តរភាព។ គ្រប់គ្រង**ព្រៃឈើ**ប្រកបដោយនិរន្តរភាព ប្រយុទ្ធប្រឆាំងនឹង**ដីរហស្ថាន** និងលុបបំបាត់ និងស្ដារ**ដីរេចរឹល** និងបញ្ឈប់**ការបាត់បង់ជីវចម្រុះ**

**គោលដៅទី ១៦៖** លើកកម្ពស់**សង្គមប្រកបដោយសន្តិភាព** និង**បរិយាបន្ន**សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ផ្ដល់សិទ្ធិទទួលបានយុត្តិធម៌សម្រាប់ទាំងអស់គ្នា និងកសាងស្ថាប័នប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ននៅគ្រប់កម្រិតទាំងអស់

**គោលដៅទី ១៧៖** ពង្រឹងមធ្យោបាយនៃការអនុវត្ត និង**ភាពជាដៃគូសកល** សម្រាប់**ការអភិវឌ្ឍប្រកបដោយចីរភាព**

ពាក្យ ឬប្រយោគដែលមានអក្សរខ្មៅក្រាស់នៅក្នុងបញ្ជីគោលដៅទាំង ១៧ គឺជាពាក្យដែលត្រូវពិភាក្សានៅក្នុងសៀវភៅសិក្សានេះទាក់ទងនឹងសុខភាព និងសុខុមាលភាព សុវត្ថិភាព និងអនាម័យ។ ពាក្យទាំងនេះបង្ហាញថា សុខភាពសិក្សាមិនគ្រាន់តែជាការអប់រំសុខភាពនៅក្នុងសាលារៀនប៉ុណ្ណោះទេ ប៉ុន្តែវាមានតួនាទីយ៉ាងសំខាន់ឆ្ពោះទៅរកការសម្រេចបានគោលដៅ SDGs និងអាចរួមចំណែកយ៉ាងសំខាន់ដល់សង្គមកម្ពុជា។ លើសពីនេះទៅទៀត ដូចមានចែងក្នុងគោលនយោបាយសុខភាពសិក្សាកម្ពុជា (ឆ្នាំ២០១៦ និង ២០១៩)[2,3] និស្សិតសាកលវិទ្យាល័យ សិស្ស និងគ្រូបង្រៀនដែលបានសិក្សាអំពីសុខភាពសិក្សាត្រូវបានរំពឹងថានឹងក្លាយជាធនធានមនុស្សដែលអាចចូលរួមចំណែកដល់សង្គមកម្ពុជាដែលរីកចម្រើនប្រកបដោយចីរភាព សន្តិភាព និងប្រកបដោយសុខភាពល្អ។

ឯកសារយោង៖


1. Cambodia Sustainable Development Goals, https://www.csdgs.org/km/
2. Ministry of Education, Youth and Sport. SCHOOL HEALTH POLICY. 2006
3. Royal Government of Cambodia. National Policy on School Health. 2019